CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៨ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ Rebecca F. Kauma, Economic and Digital Inclusion Program Manager, មន្ទីរបច្ចេកវិទ្យានិងការច្នៃប្រឌិត, 562.570.7441, Rebecca.Kauma@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចចាប់ដៃគូជាមួយនឹងអង្គការមិនរកកំរៃដើម្បីបើកដំណើរការកម្មវិធីធនធានឌីជីថលគឺ ConnectedLB

*ទីក្រុងឡុងប៊ិចត្រូវបានតែងតាំងជាក្រុងឈានមុខសម្រាប់ឌីជីថលដែលរួមបញ្ចូលឆ្នាំ ២០២០*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - មន្ទីរបច្ចេកវិទ្យានិងការច្នៃប្រឌិតរបស់ទីក្រុងឡុងប៊ិចដោយសហការជាមួយនឹងមូលនិធិបច្ចេកវិទ្យារីកចំរើនរបស់កាលីហ្វ័រញ៉ា (California Emerging Technology Fund) ព្រមទាំង EveryoneOn និង human-I-T បានដាក់ចេញនូវប្រព័ន្ធអ៊ីនធ័រណេតចំណុចកណ្តាលសម្រាប់អ្នករស់នៅទីក្រុងឡុងប៊ិចដើម្បីទទួលបានសេវាកម្មអ៊ិនធឺណិតតម្លៃទាបកុំព្យូទ័រនិងធនធានអក្ខរកម្មឌីជីថលដែលមានឈ្មោះថា ConnectedLB Platform ដោយនៅក្នុងសម្ព័ន្ធភាពជាមួយនឹងគំនិតផ្តួចផ្តើម Get Connected របស់ CETF.

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "អ៊ិនធឺរណែតមានសារៈសំខាន់ជាងពេលណាទាំងអស់។ តាមរយៈ ConnectedLB ប្រជាជនកាន់តែច្រើននឹងទទួលបានសេវាកម្មដែលមានតំលៃសមរម្យដើម្បីភ្ជាប់ទំនាក់ទំនងជាពិសេសក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ។"

ប្រព័ន្ធ ConnectedLB ផ្តល់លទ្ធភាពឲ្យអ្នករស់នៅទីក្រុងឡុងប៊ិចអាចស្វែងរកសេវាកម្មអ៊ិនធឺរណែត និងកុំព្យូទ័រដែលមានតម្លៃទាបនៅតាមតំបន់ក្នុងសង្កាត់របស់ពួកគាត់ដោយប្រើលេខកូដតំបន់របស់ពួកគាត់។ អ្នករស់នៅទីក្រុងឡុងប៊ិចអាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានសេវាកម្មអ៊ិនធឺណិតនិងកុំព្យូទ័រដែលមានតម្លៃទាបដោយផ្អែកលើការផ្ទៀងផ្ទាត់ទៅលើប្រាក់ចំណូលនិងការចូលរួមរបស់គ្រួសារគាត់នៅក្នុងកម្មវិធីអត្ថប្រយោជន៍សាធារណៈ។ ប្រព័ន្ធនេះមានទាំងភាសាអង់គ្លេសនិងអេស្ប៉ាញហើយរំពឹងថានឹងដំណើរការរហូតដល់ខែមេសាឆ្នាំ ២០២១ ឬរហូតដល់មានការជូនដំណឹងបន្ថែម។ មាតិកានៃប្រព័ន្ធគឺគ្រប់គ្រងដោយ EveryoneOn។ ដើម្បីចូលទៅកាន់ប្រព័ន្ធនេះប្រជាជនឡុងប៊ិចអាចចូលទៅកាន់គេហទំព័រ៖ everyoneon.org/longbeach។

## ទីក្រុងឡុងប៊ិចត្រូវបានតែងតាំងជាក្រុង "ឈានមុខសម្រាប់ឌីជីថលដែលរួមបញ្ចូលឆ្នាំ ២០២០" ដោយសម្ព័ន្ធឌីជីថលដែលរួមបញ្ចូលជាតិ (NDIA)

ទីក្រុងឡុងប៊ិចគឺជាយុត្តាធិការមួយក្នុងចំណោមយុត្តាធិការចំនួន ១៤ នៅក្នុងប្រទេសដែលត្រូវបានតែងតាំងជាក្រុងឈានមុខសម្រាប់ឌីជីថលដែលរួមបញ្ចូលឆ្នាំ ២០២០ ដោយសម្ព័ន្ធឌីជីថលដែលរួមបញ្ចូលជាតិ (NDIA)។ នេះជាលើកទី ២ ហើយដែលទីក្រុងទទួលបានការទទួលស្គាល់នេះ។ ការឈានមុខសម្រាប់ឌីជីថលដែលរួមបញ្ចូលគឺជាការផ្តួចផ្តើមគំនិតរបស់រដ្ឋាភិបាលក្នុងតំបន់ដែលលើកកម្ពស់ចំណេះដឹងឌីជីថលនិងអ៊ីនធឺណិតដែលមានល្បឿនលឿនសម្រាប់ប្រជាជនដែលមិនទាន់បានទទួល។

ក្រុងឈានមុខគឺជាគំរូសម្រាប់រដ្ឋាភិបាលក្នុងតំបន់ផ្សេងទៀតក្នុងការបន្តកិច្ចប្រឹងប្រែងដាក់បញ្ចូលឌីជីថលនៅក្នុងសហគមន៍របស់ពួកគាត់។ NDIA ជ្រើសរើសរដ្ឋាភិបាលក្នុងតំបន់ផ្សេងៗដោយប្រើប្រាំមួយចំណុចដូចជា៖

- បុគ្គលិកពេញម៉ោងដែលផ្តោតលើគំនិតផ្តួចផ្តើមរួមបញ្ចូលឌីជីថល។
- រដ្ឋាភិបាលក្រុងបានបង្កើតឬកំពុងបង្កើតផែនការបញ្ចូលឌីជីថល។
- រដ្ឋាភិបាលក្រុងចូលរួមក្នុងសម្ព័ន្ធភាពរួមបញ្ចូលឌីជីថល។
- រដ្ឋាភិបាលក្រុងបានធ្វើឬមានគម្រោងធ្វើការស្រាវជ្រាវស្ទង់មតិលើការចូលប្រើអ៊ីនធឺណិត។
- រដ្ឋាភិបាលក្រុងរកកម្មវិធីបញ្ចូលឌីជីថលសហគមន៍ដោយផ្ទាល់។

- រដ្ឋាភិបាលក្រុងមានឬកំពុងចាត់វិធានការដើម្បីបង្កើនលទ្ធភាពទទួលបាននូវសេវាកម្មអ៊ីនធឺណិតល្បឿនលឿនតាមផ្ទះ។

ព័ត៌មានបន្ថែមទាក់ទងនឹងគំនិតផ្តួចផ្តើមនេះមាននៅលើគេហទំព័រការរាប់បញ្ចូលឌីជីថលរបស់ទីក្រុង។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #